+855 (0)17774864
www.sasabassac.com

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

សា-សាបាសាក់ SA SA BASSAC

# នៅក្នុង

## ដោយ ហេង វ៉ារុធ

វ៉ារុធបានហ្វឹកហាត់ដើម្បីក្លាយជាវិចិត្រករបែបគំនូរដូច។ ក្រោយមកនៅឆ្នាំ ២០០៧ វ៉ារុធ បានចាប់ផ្តើមប្រឡូកក្នុងជំនាញថតរូប ដែលផ្តល់អោយគាត់នូវមធ្យោបាយមួយកាន់តែផ្ទាល់ ស្និតស្នាល និងផុសចេញតាមអារម្មណ៍ ដើម្បីសិក្សាពីសម្តែងអារម្មណ៍របស់គាត់ តាមរយៈការយកខ្លួនឯងធ្វើជាតួអង្គតំណាងនៅក្នុងស្នាដៃសិល្បៈ។ ការបង្កើតរូបបានក្លាយជាផ្នែកដ៏សំខាន់មួយក្នុងការស្វែងយល់ពីខ្លួនគាត់ និងមធ្យោបាយក្នុងការចាប់យកនូវទស្សនៈនៃអត្តសញ្ញាណ និងបុគ្គលនិយម ក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។

ដោយពិនិត្យមើលលើភាពជាបុរស និងភាពជាមនុស្ស ស្នាដៃរូបភាពរបស់គាត់កាន់តែមានភាពឯកជន ពេលខ្លះមានភាពអាក្រាត ពេលខ្លះមានលក្ខណៈសម្តែង ហើយខ្លះមានពណ៌ ខ្លះសខ្មៅ។ វ៉ារុធ និយាយថា «ភាពអាក្រាត ជាពិសេសនៅក្នុងវប្បធម៌កម្ពុជា ស្តាប់ទៅមិនសមរម្យ ហើយពេលខ្លះគួរអោយរំខាន ព្រោះវាផ្សារភ្ជាប់ទៅនឹងភាពជាឯកជននៃរូបរាងកាយ ដែលយើងជាទូទៅមិនលើកយកមកនិយាយ។ វាក៏ទាក់ទងទៅនឹងភាពអាម៉ាស និងភាពថ្លៃថ្នូ ដូច្នេះហើយទើបយើងហាក់ដូចជាព្យាយាមលាក់បាំងវា។ រូបរាងកាយរបស់យើង មុខរបស់យើង ស្បែករបស់យើង គឺជាការផ្សារភ្ជាប់គ្នារវាងអារម្មណ៍នៅខាងក្នុង និងអ្វីដែលយើងសម្តែងចេញមក នៅក្នុងការរស់នៅរាល់ថ្ងៃ និងវប្បធម៌ជាក់លាក់របស់យើង»។

សម្រាប់ស្នាដៃ *នៅក្នុង* វ៉ារុធពិនិត្យទៅលើចន្លោះនៃភាពជាឯកជននិងសាធារណៈ ដោយចាប់ផ្តើមពីរូបភាពរបស់ខ្លួនគាត់ផ្ទាល់ រួមទាំងរូបមុខ និងរូបអាក្រាតរបស់គាត់។ រូប Dream គឺជារូបបែបអរូបីមួយដកស្រង់ចេញពីស្នាដៃពិព័រណ៍តែម្នាក់ឯងលើកទី១របស់គាត់។ ចំណែករូប Screenshot I និង II គឺជារូបបែបលាក់កំបាំង មួយជារូបមុខពាក់វ៉ែនតាខ្មៅ និងមួយទៀតជារូបមុខបាំងដោយដៃ និងពន្លឺចេញពីកុំព្យូទ័រតំណាងអោយយុគ្គសម័យឌីជីថល។ ការសិក្សាអំពីរូបបែបអាក្រាតរបស់វ៉ារុធ ហាក់ដូចជារំលឹកដល់ទំនៀមទម្លាប់ពីកន្លែងនិងពេលវេលាមួយផ្សេងទៀត។ ការងារបែបអាក្រាតលើកទី១របស់វ៉ារុធនៅទីសាធារណៈ គឺបានធ្វើឡើងនៅក្នុងអគារចាស់ទ្រុឌទ្រោមនៅក្នុងភ្នំពេញ។ ដោយមានលក្ខណៈមិនច្បាស់លាស់ និងបរិកាសនៅក្នុងរូបភាពស្រដៀងទៅនឹងការងាររបស់ Francesca Woodman រូបដំបូងរបស់វ៉ារុធមានលក្ខណៈស្រមោលអោនទៅមុខកំពុងចុះពីលើជណ្តើរ ( The Building )។ ចំនែករូបមួយទៀតស្ថិតនៅក្នុងបន្ទប់ដោយមានសម្ភារៈមួយចំនួនដូចជាសៀវភៅ ( The Mainson )។ រូប Forest Walk I និង II ផ្សារភ្ជាប់ទៅនឹងចេតនាទាំងបែបរូបថតនិងបែបគំនូរ ស្រដៀងទៅនឹងស្នាដៃរបស់សិល្បករអាមេរិក Thomas Eakins ដែលបង្ហាញពីបុរសក្មេងៗជាមួយនឹងធម្មជាតិ និងការតាំងចិត្តដ៏កម្រក្នុងការសិក្សាពីរូបអាក្រាតរបស់មនុស្សប្រុស នៅក្នុងសង្គមវប្បធម៌កាលនោះ។

ប្រភពរូបភាពទាំងនេះ ដែលដើមឡើយជាស្នាដៃដ៏ចម្បងស្រាប់ទៅហើយ ត្រូវបានយកមកតំរៀបទៅជារូបភាពតូចៗផ្តុំគ្នា ក្នុងទម្រង់រូបភាពបែកពណ៌នៅលើផ្ទាំងក្រណាត់។ សិល្បករបានផាត់ពីលើនូវពណ៌បែបស្រងូតស្រងាត់ បង្កើតបានជាគំនូរដ៏ពិសេសនៃរូបថតតូចៗទាំងនេះ។ ពេលមើលពីចម្ងាយ រូបទាំងអស់នេះហាក់ដូចជាអនុញ្ញាតអោយអ្នកទស្សនាស្វែងរកបុគ្គលនៅក្នុងរូប។ តាមរយៈការស្វែងរកបុគ្គលនេះ យើងនឹងត្រឡប់មករកភាពជាសហគមទាំងមូល។

**អំពីសិល្បករ**

ហេង វ៉ារុធ បានកើតនៅឆ្នាំ ១៩៨៥ នៅទីក្រុងភ្នំពេញ។ គាត់បានទទួលបរិញ្ញាប័ត្រផ្នែកគំនូរពីសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅឆ្នាំ ២០០៦។ ស្នាដៃពិព័រណ៍តែម្នាក់ឯងរបស់គាត់រួមមាន Dream ក្នុងមហោស្រពរូបថតភ្នំពេញ វិចិត្រសាល Java ( ២០០៧ ) និង Nude ក្នុងមហោស្រពរូបថតភ្នំពេញ វិចិត្រសាល XEm ( ២០09 )។

# Innermost

## Heng Ravuth

Trained as a realist painter, in 2007 Heng turned to photography, allowing him a more immediate, intimate, and intuitive way to study how self-representations can or cannot express his inner feelings. Image making became integral to his search for self-understanding and a way to cope with the relatively new concept of identity and individualism in today's Cambodia.

Exploring both maleness and humanness, his photographic serial work became increasingly private, sometimes nude, sometimes performative, in both color and black and white. Says the artist, "Nudity, particularly in Cambodian culture, sounds uncomfortable and sometimes disturbing as it strongly connects to the very intimate privacy of bodies that we usually don't talk about. It also connects to shame and dignity and therefore we seem to try to hide it. Our bodies, our face, our skin are the connection between what we feel inside and how we express this in our daily lives, our specific cultures."

For *Innermost*, Heng plays with this private/public gap, beginning with a selection of intimate self-portraits from his archive, including hidden faces and nude figure studies. *Innermost, Dream* is an abstract profile from the artist's first ever solo exhibition, while *Innermost, Screenshot I* and *II* are hidden portraits, one face behind sunglasses, one with head in hand; diffuse light from a computer flash reference our digital age. It is Heng's studies of the nude figure that echo traditions from another place and time. Heng's first sessions in public space were within deteriorating iconic buildings in Phnom Penh. Francesca Woodman-like in their elusiveness and atmosphere, his initial poses were shadowy, hunched over while descending a staircase (*Innermost, The Building*), while later he posed in large bare rooms with props such as a book (*Innermost, The Mansion*). *Innermost, Forest Walk I* and *II* connect to both the photographic and painterly intentions of American artist Thomas Eakins in their portrayal of youthful men at one with nature, and the rare veritable commitment to studying the male nude against cultural constructs of their time.

These source images, originally prominent works in themselves, have been humbled to a thumbnail scale typical of social media profiles today and multiplied on contact sheets to form a pixilated wallpaper over parts of the canvas. The artist scratched into this layer of emulsion and covered parts of its surface with somber colors, crafting new, iconic and painterly versions of these small photographs. Viewed from a distance, the whole invites us to search for the individual. Discovering the individual, we are drawn back to the whole.

**About the Artist**

Heng Ravuth (b. 1985, Phnom Penh) earned a BA in Painting, Royal University of Fine Art, Phnom Penh, 2006. Select solo exhibitions include *Dream*, PhotoPhnomPenh / Java Café and Gallery (2007) and *Nude*, PhotoPhnomPenh / XEm Galerie, Phnom Penh (2009).

# នៅក្នុង
## ដោយ ហេង រ៉ាវុធ

# Innermost
## Heng Ravuth

9 December 2011 – 8 January 2012


*Innermost*, *Screenshot I*, 110x165cm, 2011


*Innermost*, *Dream*, 110x165cm, 2011


*Innermost*, *The Mansion* (detail), 2011


*Innermost*, *The Mansion*, 100x165cm, 2011